**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ៩៤ប្រ
ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៦
**សាលដីកា**
លេខៈ២៣៤
ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៦

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៦ ដោយមានសមាសភាពដូចតទៅៈ
១-ឯកឧត្តម .......... ជាប្រធាន
២-លោក ...............ជាចៅក្រមរបាយការណ៍
៣-លោក ............. ជាចៅក្រម
៤-លោក ................ ជាចៅក្រម
៥-លោក ................. ជាចៅក្រម

**ក្រឡាបញ្ជី**
-លោក ...............

**តំណាងមហាអយ្យការ**
-ឯកឧត្តម .............. ជាអគ្គព្រះរាជអាជ្ញារង

ដើម្បី ជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ០៥(ជ) ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៦ នៃសំណុំរឿងរដ្ឋប្បវេណីលេខៈ០១ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០០៦ របស់សាលាឧទ្ធរណ៍។

រវាងដើមចោទឈ្មោះចាន់ ចហ (ជាម្ចាស់បណ្តឹងសាទុក្ខ)ភេទប្រុស អាយុ៣៩ឆ្នាំជាតិខ្មែរ មុខរបរ អាជីវករកិនស្រូវមានទីលំនៅ ភូមិស្ពានថ្ម ឃុំស្ទឹងត្រែងស្រុកស្ទឹងត្រែង ខេត្តស្ទឹងត្រែងតំណាងដោយឈ្មោះជារដ្ឋា និងចុងចម្លើយឈ្មោះជទ (ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៤៥ឆ្នាំ ជាតិខ្មែរមុខរបរលក់-ដូរ មានទីលំនៅ ភូមិត្រពាំងព្រីង ឃុំស្ទឹងត្រែង ស្រុកស្ទឹងត្រែង ខេត្តស្ទឹងត្រែង ។

មានមេធាវីលោក ......... ។

**កម្មវត្ថុបណ្តឹងៈ** ប្តឹងកិច្ចការប្រញាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៤០ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៦ របស់ឈ្មោះជា រដ្ឋា បានប្តឹងមិនសុខ ចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងព្ធប្បវេណីលេខ៩៤ប្រ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៦ របស់តុលាការកំពូល។

តាមពាក្យបណ្តឹងសុំដីកាសម្រេចតាមពាក្យសុំចុះថ្ងៃទី១១-៨-២០០៥ របស់ឈ្មោះកាន់ ចហ បានប្តឹងសុំ ការសម្រេចតាមពាក្យសុំយកបង្គោលរបង និងខ្ទម ដែលលោកព្រះរាជអាជ្ញាអមតុលាការខេត្តស្ទឹងត្រែងយកទៅ ទុកនៅមន្ទីសុរិយោដីខេត្ត ដោយហេតុថាកាលពីថ្ងៃទី០៩-៨-២០០៥ លោកព្រះរាជអាជ្ញាអមតុលាការខេត្តស្ទឹងត្រែងបានយកកំលាំងកងរាជអាវុធហត្ថទេត្តទៅចុះរុះរើ និងវាយកំទេចបង្គោលស៊ីម៉ង់ត៍ និងខ្ទមហើយបានយកមកទុកនៅមន្ទីរៀបចំដែនដីនគរូបនីយកម្មខេត្ត ។ហើយនៅថ្ងៃទី១០-០៨-២០០៥ ខ្លួនដាក់ពាក្យបណ្តឹងសុំយកបង្គោលរបង និង ខ្ទមទៅ

ឯកឧត្តមអភិបាលខេត្ត ដើម្បីឱ្យគាត់ជួយដោះស្រាយ ពេលនោះគាត់បានធ្វើលិខិតមកកាន់ តុលាការខេត្តដើម្បីជាសមត្ថកិច្ច ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី១០-៨-២០០៥ របស់ឈ្មោះកាន់ ចហ បានប្ដឹងពីឈ្មោះសុខ ហេង.សរ វ៉ានិង ហង្សចន្ទ បានរួមគំនិតគ្នាឱ្យលោក ព្រះរាជអាជ្ញាចេញលិខិតឱ្យPMចុះរុះរើបង្គោលរបងឈើ និងខ្ទម ហើយវាយ កំទេចបង្គោលរបងស៊ីម៉ង់ត៍ខូចខាតទាំងស្រុងកាលពីថ្ងៃទី០៩-៨-២០០៥ ។ ដោយសំអាងហេតុថាដីនេះខ្លួនបានកាន់ កាប់ និង ដាក់របងតាំងពីឆ្នាំ១៩៩៧ ដែលមានសាក្សីដឹងឮ មានឈ្មោះលី ស៊ីថាន់ ហ្សេង ចាន់លក្ខ័ ហ៊ុន ឡុង, ស៊ឹប សារឿន នូវ សារុន ជា ចាន់ មាស សេក ជា ភិរម្យ និត សារ៉េត, ហ្សេង គឹមស្រួយ ជិន សារិន អ្នកទាំងនោះជា អ្នកដឹងឮនិងផ្ដិតមេដៃទទួលស្គាល់ជាដីរបស់ខ្លួនផង ។

នៅថ្ងៃទី០៩-១០-២០០៤ វេលាម៉ោង៩,២០នាទី លោកមេឃុំ មេប៉ុស្ដិ៍ ព្រមទាំងសាក្សីចុះធ្វើកំណត់ហេតុទាញខ្សែតម្រង់ព្រំដីយល់ព្រមទាំងអស់គ្នាថាមិនមានជំលោះគ្នាតទៅទៀតឡើយ ហើយមេឃុំបានចុះហត្ថលេខា បោះត្រា និង សាក្សីទាំងអស់បានយល់ព្រមផ្ដិតមេដៃទាំងអស់គ្នា ។ ខ្លួនសំណូមពរដល់ឯកឧត្តមអភិបាលខេត្តជួយរកយុត្តិធម៌ ដល់រូបខ្លួន និងសុំយកបង្គោលរបងដែលមន្ទីរសុរិយោដីខេត្តរក្សាទុកយកមកដាំរក្សាភាពដើមវិញ សុំសំណងការខូចខាតរបង និងខ្ទមចំនួន៤០០០,០០០៛ (បួនលានរៀល) ។

បានឃើញដីកាសម្រេចតាមពាក្យសុំលេខ៣៣៧ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៥ របស់តុលាការ ខេត្តស្ទឹងត្រែងដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្ដឹងសុំដីកាសម្រេចតាមពាក្យសុំរបស់ឈ្មោះកាន់ ចហ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៥ ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ ។

២ - ទទួលលិខិតលេខ៣៩៥ សាលាខេត្ត ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៥ ទុកជាត្រឹមត្រូវតាមច្បាប់តទៅ ។

៣ - ប្រគល់បង្គោលរបងដែលបានយកមករក្សាទុកនៅមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដីខេត្ត ឱ្យទៅឈ្មោះកាន់ ចហ យកទៅដាំឱ្យបានដូចដើមវិញ ដោយហាមគ្រប់ភាគីទាំអស់សង់បង្គោល ថ្មីបន្តហាមដាំដុះលើដីកំពុងមានទំនាស់ជាដាច់ខាត ។

៤- បង្គាប់មកសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់អនុវត្តដីកាឱ្យបានសម្រេច។

- ដីកានេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

បានឃើញ បណ្ដឹងទាស់ចុះថ្ងៃទី១៤-៨-២០០៥ របស់ឈ្មោះជទ បានប្ដឹងមិនសុខចិត្តនឹងដីកាសម្រេច តាមពាក្យសុំត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

បានឃើញ ដីកាសម្រេចកិច្ចកាប្រញាប់លេងៈ០៧ប្រ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៥ របស់តុលាការខេត្ត ស្ទឹងត្រែង ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្ដឹងទាស់របស់ឈ្មោះជទ ចុះថ្ងៃទី១៤-៨-២០០៥ ជាដើមបណ្ដឹងទាស់ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-តម្កល់ដីកាសម្រេចតាមពាក្យសុំលេខ ៣៣៧ ចុះថ្ងៃទី១២-៨-២០០៥ ទុកជាបានការទាំងស្រុងដដែល ។

៣-រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន២០០០៛ គឺៈ ពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹង១៨០០៛ រង្វាប់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛ ដែលដើមបណ្ដឹងបង់ទុករួចមកហើយ ។

៤-ដីកាសម្រេចកិច្ចការប្រេញាប់នេះជំនុំជំរះជាសាធារណៈ ចំពោះមុខគូភាគីមានប្រសិទ្ធិភាពអនុវត្តភ្លាមៗ ទោះជាមានបណ្តឹងឧទ្ធរណ៍ក៏ដោយ បើភាគីណាមិនសុខចិត្តបើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញ បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៥ ឈ្មោះជទ បានប្តឹងមិនសុខចិត្តនិងដីកាសម្រេច កិច្ចការប្រញាប់របស់តុលាការខេត្តស្ទឹងត្រែង ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ០៥(ជ) ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៦ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៥ របស់ឈ្មោះជទ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈដីកាសម្រេចកិច្ចការប្រញាប់លេខៈ០៧ប្រ.ក ចុះថ្ងៃទី០២-១២-២០០៥ របស់តុលាការ ខេត្តស្ទឹងត្រែង ។

៣-បង្គាប់ឱ្យអាជ្ញាធរមានសមត្ថកិច្ចអនុវត្តតាមលិខិតលេខ១៣៥ដរសស ចុះថ្ងៃទី៥-៨-២០០៥ របស់ប្រធានមន្ទីរៀបដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដីខេត្តស្ទឹងត្រែង ដោយបង្គាប់ឲ្យអាជ្ញាធរមាសមត្ថកិច្ចចុះរុះរើបង្គោលរបងឈើ ខ្ទម ចេញពីដីទំនាស់ឈ្មោះជទ ។

៤-កាត់យកប្រាក់ប្រដាច់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣០០០៛ គឺ ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង២.៥៥០៛ វង្វាន់កក្រឡាបញ្ជីកាន់ហឹបប្រាក់ ៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ និង អាជ្ញាធរតុលាការចំនួន១០០០០៛ ។

៥-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខដើមចោទ និងមេធាវីការពារដើមចោទកំបាំងមុខចុងចម្លើយ ។ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៤០ ចុះថ្ងៃទី១០ ខែតុម្ភៈ ឆ្នាំ២០០៦ របស់ឈ្មោះដា រដ្ឋា តំណាងឱ្យឈ្មោះកាន់ ចហ បានប្តឹងមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសារណារបស់ឈ្មោះកាន់ ចហ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦ ។

បានឃើញ សារណាតបរបស់ឈ្មោះជទ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៦ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថាៈ បណ្តឹងសាទុក្ខរបស់លោកដា រដ្ឋា តំណាងឱ្យលោកកាន់ ចហ ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមក ពិនិត្យ-ពិចារណា ។
សាលដីការដ្ឋប្បវេណីរបស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះ សម្រេចតាមច្បាប់ ។

លោកដា រដ្ឋា បានឆ្លើយថា៖ មកពីការសម្រេចរបស់សាលាឧទ្ធរណ៍មានលក្ខណៈខុសគ្នាពីខ្លឹមសារនៃកិច្ចការប្រញាប់ ត្រូវទុកបង្គោលឱ្យនៅដដែលដោយរក្សាភាពដើមសិន ទើបពុំមានការប៉ះពាល់ដល់អង្គសេចក្តី ។

អ្នកស្រីជទ បានឆ្លើយថា ដីនេះខ្លួនមិនទាន់មានបណ្ណ័សំគាល់អចលនវត្ថុទេ ប៉ុន្តែខ្លួនបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ចុះថ្ងៃទី១៥-៩-២០០៤ ដោយមានការទទួលស្គាល់ពីមេឃុំ ប៉ាង ឡា ទៀតផង ។

មេធាវីលោក......... ការពារឱ្យអ្នកស្រីជ្រូទូច បានធ្វើសេចក្តីសន្និដ្ឋានថា រឿងនេះគូភាគីនៃរឿងក្តីបានឆ្លើយថាមិនទាន់មានប័ណ្ណកាន់កាប់ទេ ប៉ុន្តែដីនេះកូនក្តីរបស់ខ្លួនបានទិញពីឈ្មោះសន រ៉ា មានទំហំ២១៥មx ២២០ម ស្ថិតនៅ

ក្នុងភូមិស្រែពោធិ ដោយមានលោកមេឃុំបញ្ជាក់ ព្រមទាំងមានសាក្សីដឹងឮទាំងអស់ បង្គោលដែលកូនក្តីរបស់ខ្លួនដាំនោះត្រូវគេទុកពីអក្សផ្លូវចំងាយ៥០ម ។

ការអះអាងរបស់លោកជា រដ្ឋា មុននេះមិនមានភស្តុតាងណាបញ្ជាក់តាមផ្លូវច្បាប់ឡើយ ដែលជាការខុសឆ្គងនឹងមាត្រាទី៦ និង៣៨ នៃច្បាប់ភូមិបាលឆ្នាំ២០០១ ហើយ ។

តាមនីតិវិធីចាត់ការ របស់តុលាការខេត្តស្ទឹងត្រែងគឺមានចេតនាអូសបន្លាយពេលវេលាទុកឱ្យយូរដោយផ្អើយ ទៅនឹងខ្លឹមសារនៃកិច្ចការប្រញាប់ ។

តុលាការខេត្តស្ទឹងត្រែងបានសម្រេចយកករណី វិវាទដីធ្លីដែលគ្មានប័ណ្ណកម្មសិទ្ធិមកធ្វើការសម្រេចចេញវិធានការបណ្តោះអាសន្នទៅវិញ ព្រោះរឿងនេះមិនមែនជាសមត្ថកិច្ចរបស់តុលាការទេ នាំឱ្យមានការផ្ទុយស្រឡះពីប្រកាសអន្តរក្រសួងសេ៥០២ ប្រក០៣ និង មាត្រា ៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

**<u>សំណូមពរ</u>** សុំតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអាយុការ

-ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី និងសេចក្តីសន្និដ្ឋានរបស់មេធាវីចុងចម្លើយ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៤០ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៦ របស់លោកជា រដ្ឋា តំណាងឱ្យ លោក កាន់ ចហ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមក ជំនុំជំរះ បានដោយយោង តាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលតុសាការខេត្តស្ទឹងត្រែងសម្រេចចេញដីកាតាមពាក្យសុំ និងដីកាសម្រេចកិច្ចការប្រញាប់ ប្រគល់បង្គោលរបងឱ្យទៅលោកកាន់ ចហ យកទៅដាំដូចដើមវិញ ដោយពុំមានរឿងនៃអង្គសេចក្តី ជាការខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ ។

-យល់ឃើញថា ដីទំនាស់រវាងលោកកាន់ ចហ និងអ្នកស្រីដទ គ្មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ទេ ហើយកំពង់ស្ថិតក្នុងសមត្ថកិច្ចគណៈកម្មការសុរិយោដីស្រុកស្ទឹងត្រែងនៅឡើយ ដូច្នេះការដែលតុលាការខេត្តស្ទឹង ត្រែង លើកបញ្ហានេះមកដោះស្រាយមុនរឿងអង្គសេចក្តីមកតុលាការជាការខុសសមត្ថកិច្ចដែលត្រូវទុកជាមោឃៈ។

-យល់ឃើញថា ការដែលតំណាងដើមចោទលើកឡើងថា បង្គោលរបង ដែលលោកបានដាំនោះមានយូរមក ហើយដែលគប្បីរក្សាភាពដើមនោះ តុលាការ ពុំពិចារណាទេ ពីព្រោះពុំមែនជាសត្ថកិច្ចរបស់តុលាការ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ០៥(ជ) ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៦ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ហើយ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្ដីចំពោនមុខតួក្ដី

១ - ទទួលបណ្ដឹងសាទុក្ខលេខ៨៤០ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៦ របស់ឈ្មោះជា រដ្ឋ តំណាងឱ្យលោកកាន់ ចហ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ០៥(ជ) ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៦ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន១៩០០០៛ ដែលអ្នកស្រីជទ បានបង់ជួស គឺ៖

-ពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹងចំនួន ៤០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សម្រាប់ជារង្វាន់ក្រឡបញ្ជីកាន់ហឹបប្រាក់

-ចំណាយលើការប្រគល់ដីកាកោះចំនួន ១៥០០០៛ សរុប ១៩០០០៛ ហើយតម្រូវឱ្យលោកកាន់ ចហ សងប្រាក់ចំនួន១៩០០០៛ នេះទៅអ្នកស្រីជទ វិញ។

៥-សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៦ ។